## សាកលវិទ្យាល័យនៃសាលាពេទ្យ Massachusetts

គណៈកម្មាធិការ សំរាប់ការពារមនុស្សចូលរួមក្នុងការស្រាវជ្រាវ
UMass Memorial Medical Center

# ក្រដាសបំពេញទំរង់ខ្លី ជាឯកសារការយល់ព្រមលាយល័ក្ខណ៍អក្សរ សំរាប់មនុស្ស ដែលមិនចេះនិយាយភាសាអង់គ្លេស

### សេចក្តីយល់ព្រម ដើម្បីចូលរួមក្នុងការស្រាវជ្រាវ

ឈ្មោះ PI: ________________________________________ លេខបង្កាន់ដៃ: ______________

លោកអ្នក ត្រូវបានសុំឲ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយ។

មុននឹងលោកអ្នកយល់ព្រម អ្នកសង្កេតការណ៍ត្រូវប្រាប់លោកអ្នក អំពីគោលបំណង ទំរង់ការ និងរយៈពេលនៃការស្រាវជ្រាវ; ទំរង់ការអ្វីមួយដែលជាការពិសោធន៍; ហេតុផលនៃភាពគ្រោះថ្នាក់អ្វីមួយដែលដឹងជាមុន ភាពពិបាក និងផលប្រយោជន៏នៃការស្រាវជ្រាវ; ហើយនិងទំរង់ការ ឬការព្យាបាលផ្សេងទៀត ដែលអាចនឹងផ្តល់ផលប្រយោជន៍; ព្រមទាំងរបៀបសំងាត់ដែលនឹងរក្សាភាពទុក។

នៅទីណាអាចអនុវត្តបាន អ្នកសង្កេតការណ៍ក៏ត្រូវប្រាប់លោកអ្នកដែរ ពីការសងប្រាក់ ឬវិធីព្យាបាលអ្វីមួយដែលមាន បើសិនមានរបួស; ភាពគ្រោះថ្នាក់ដែលមើលមិនដឹងជាមុន; កាលៈទេសៈនៅពេលអ្នកសង្កេតការណ៍អាចនឹងបញ្ឈប់ការចូលរួមរបស់លោកអ្នក; តម្លៃអ្វីមួយដែលបន្ថែមដល់លោកអ្នក; មានអ្វីកើតឡើង បើសិនលោកអ្នកសំរេចចិត្តឈប់ចូលរួម; គេនឹងបានប្រាប់លោកអ្នកនៅពេលណា អំពីការរកឃើញថ្មី ដែលអាចនឹងប៉ះពាល់ដល់ការយល់ព្រមរបស់លោកអ្នកដើម្បីចូលរួម; និងចំនួនមនុស្សដែល នឹងចូលរួមក្នុងការសិក្សា។

បើសិនលោកអ្នកយល់ព្រមចូលរួម លោកអ្នកត្រូវតែបានទទួលសំណៅនៃឯកសារនេះ ដែលបានចុះហត្ថលេខា ព្រមទាំង សេចក្តីសង្ខេបជាលាយល័ក្ខណ៍អក្សរនៃការស្រាវជ្រាវ។

លោកអ្នកអាចទាក់ទង ------------ តាម ------------ នៅពេលណាលោកអ្នកមានសំណួរអំពីការស្រាវជ្រាវ។

លោកអ្នកអាចទាក់ទង ការិយាល័យកម្មវត្ថុការស្រាវជ្រាវ (Research Subjects Office) តាមលេខ 508-856-4261 បើសិនលោកអ្នកមានសំណួរ អំពីសិទ្ធិរបស់លោកអ្នក ជាអ្នកចូលរួមការស្រាវជ្រាវ ឬត្រូវធ្វើអ្វី បើសិន លោកអ្នកមានរបួស។

ការចូលរួមរបស់លោកអ្នកក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាការស្ម័គ្រចិត្តទាំងស្រុង។ បើលោកអ្នកសំរេចចិត្តមិនចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះទេ វានឹងមិនប៉ះពាល់ដល់ការថែទាំដែលលោកអ្នកទទួលឡើយ។ បើសិនលោកអ្នកប្រកែកមិនចូលរួម ឬសំរេចចិត្តឈប់ លោកអ្នកនឹងមិនទទួលពិន័យ ឬបាត់បង់អត្ថប្រយោជន៍ឡើយ។

ការចុះហត្ថលេខាលើឯកសារនេះ មានន័យថាការសិក្សាស្រាវជ្រាវ រួមទាំងព័ត៌មាននៅខាងលើ ត្រូវបានរៀបរាប់ជូនលោកអ្នក ដោយផ្ទាល់មាត់ ហើយថា លោកអ្នកយល់ព្រមចូលរួម ដោយស្ម័គ្រពីចិត្ត។

________________________________________

ហត្ថលេខាអ្នកចូលរួម ខែថ្ងៃឆ្នាំ

________________________________________

ហត្ថលេខាសាក្សី ខែថ្ងៃឆ្នាំ